ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 31 / 05 / 2013
ម៉ោង (Time/Heure): 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

002/19-09-2007-ECCC/TC
E1/166

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ អង្គារ៍ ទី ២៩ ខែ មករា ឆ្នាំ ២០១៣

## សវនាការលើអង្គសេចក្តី- ថ្ងៃទី ១៥៣

រៀបចំដោយ: សែ កុលវុឌ្ឍី និង Roger PHILLIPS

| |
|---|
| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក ដាវ អានសាន, លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក Dale Lysak |
| ជនជាប់ចោទ៖ អៀង សារី (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael G. Karnavas |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោកស្រី Anta GUISSE |

| |
|---|
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT, លោក ពេជ អង្គ លោក វ៉ែន ពៅ, លោកស្រី Christine MARTINEAU. |
| សាក្សី៖ លោក Al ROCKOFF (TCW-565) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី ស្ញ សុទ្ធាវី |
| ផ្សេងៗ៖ កញ្ញា Pauline RODOT |

**ពេលវេលាទូទៅរបស់តុលាការ៖**

| ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣ | ចាប់ផ្តើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១១.៥៥ |
|---|---|---|
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣៥ | បញ្ចប់ម៉ោង៖ ១១.00 |
| | | ចំនួនម៉ោងសរុបរបស់តុលាការ៖ ០២ ម៉ោង និង ២៥ នាទី |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការក្នុងអំឡុងពេលនៃការស្តាប់សក្ខីកម្មសាក្សី Al ROCKOFF (TCW-565) | អង្គជំនុំជម្រះ | ០៩.០៥ | ០៩.០៥ |
| ការលះបង់សិទ្ធិមានវត្តមានក្នុងដំណើរការសវនាការ | អង្គជំនុំជម្រះ | ០៩.០៥ | ០៩.០៦ |
| ការតាំងសំណួរទៅសាក្សី Al ROCKOFF (TCW-565) | មេធាវីការពារក្តី នួន ជា<br>មេធាវីការពារក្តី ខៀវ សំផន | ០៩.០៧<br>១០.១៨ | ១០.១៨<br>១១.៣៨ |
| ការអន្តរាគមន៍របស់សហព្រះរាជអាជ្ញា | សហព្រះរាជអាជ្ញា | ១១.១៦ | ១១.១៦ |
| សំណើសុំលះបង់សិទ្ធិមានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការលើការបង្ហាញឯកសារគន្លឹះសំខាន់ៗថ្ងៃទី ៣០ និង ៣១ ខែ មករា | មេធាវីការពារក្តី ខៀវ សំផន | ១១.៣៦ | ១១.៣៨ |
| សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការទទួលយកឯកសារ | សហព្រះរាជអាជ្ញា | ១១.៣៩ | ១១.៣៩ |
| សេចក្តីសម្រេចរបស់អង្គជំនុំជម្រះទាក់ទងនឹងនីតិវិធីនៃការទទួលយកឯកសារ | អង្គជំនុំជម្រះ | ១១.៤០ | ១១.៤៥ |

| | | | |
|---|---|---|---|
| ការបញ្ជាក់អំពីការធ្វើសវនាការលើការបង្ហាញឯកសារ | អង្គជំនុំជម្រះ | ១១.៤៧ | ១១.៥២ |

**<u>សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>សំណើសុំលះបង់សិទ្ធិមានវត្តមាននៅបន្ទប់សវនាការក្នុងអំឡុងពេលស្ដាប់សក្ខីកម្មសាក្សី TCW-565</u>**

ជនជាប់ចោទ អៀង សារី តាមរយៈមេធាវីរបស់គាត់បានស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការដោយសារមូលហេតុសុខភាពសម្រាប់រយៈពេលពេញមួយថ្ងៃ។ អង្គជំនុំជម្រះបានសម្រេចទទួលយកសំណើសុំនេះ ដោយអនុញ្ញាតិឱ្យ អៀង សារី ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>ការលះបង់សិទ្ធិមានវត្តមានក្នុងដំណើរការសវនាការស្ដាប់សក្ខីកម្មសាក្សី TCW-565</u>**

ជនជាប់ចោទ នួន ជា តាមរយៈមេធាវីការពារក្ដីរបស់គាត់ បានដាក់លិខិតលះបង់សិទ្ធិមានវត្តមានក្នុងអំឡុងពេលនៃការស្ដាប់សក្ខីកម្មសាក្សី TCW-565 (E257/1) ដោយសារតែមូលហេតុសុខភាពដែលគាត់កំពុងតែសម្រាកព្យាបាលសុខភាពនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

**<u>ការបន្តតាំងសំណួរទៅសាក្សី AL Rockoff (TCW-565)</u>**

មេធាវីការពារក្ដី នួន ជា បានចាប់ផ្ដើមតាំងសំណួរទៅសាក្សី AL Rockoff បន្ទាប់មកមេធាវីការពារក្ដី ខៀវ សំផន បានតាំងសំណួរនិងបញ្ចប់ការតាំងសំណួរទៅសាក្សី។

**<u>ការជំទាស់ដោយសហព្រះរាជអាជ្ញា</u>**

មេធាវីការពារក្ដីបានតាំងសំណួរទៅសាក្សីដើម្បីបានទទួលព័ត៌មានថាតើសាក្សីមានបានស្ដាប់ចម្លើយដោយសហចៅក្រមស៊ើបអង្កេតដែរឬទេ។ សហព្រះរាជអាជ្ញា បានជំទាស់ចំពោះភាពពាក់ព័ន្ធទៅនឹងសំណួរនេះ និងបានរំលឹកអង្គជំនុំជម្រះថា សាក្សីនេះមិនមានភារកិច្ចក្នុងការយល់អំពីរចនាសម្ព័ន្ធរបស់តុលាការនេះទេ។ អង្គជំនុំជម្រះបានសម្រេចមិនឱ្យសាក្សីឆ្លើយតបទៅនឹងសំណួរទេដោយសារតែសំណួរមានលក្ខណៈច្រំដែរ។

សហព្រះរាជអាជ្ញាក៏បានជំទាស់មិនឱ្យទទួលយកខ្សែវីដេអូរឿង វាល ពិឃាត ជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ។

**<u>ការកត់សម្គាល់លើការស្នើសុំបង្ហាញឯកសារថ្មីដែលមិនមាននៅក្នុងបញ្ជីស្នើសុំរបស់ភាគី</u>**

មេធាវីការពារក្ដី ខៀវ សំផន បានធ្វើការកត់សម្គាល់លើបញ្ហាឯកសារដែលមិនមាននៅក្នុងបញ្ជីស្នើរបស់ ភាគី

គឺឯកសារលេខ D291/6.3.2.31 ដែលអង្គជំនុំជម្រះសម្រេចមិនអនុញ្ញាតឱ្យក្រុមខ្លួនប្រើប្រាស់ឯកសារនោះ។ សហព្រះរាជអាជ្ញាបានឆ្លើយតបថា នីតិវិធីនៃការដាក់បង្ហាញឯកសារភាគីត្រូវតែគោរព សហព្រះរាជអាជ្ញាមិនជំទាស់ចំពោះការប្រើប្រាស់ឯកសារថ្មីនោះទេ ប៉ុន្តែមេធាវីការពារក្តី ខៀវ សំផន ត្រូវតែស្នើសុំដាក់ឯកសារនោះសិន ទើបអាចប្រើប្រាស់ឯកសារថ្មីនោះបាន។ អង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងអនុវត្តទៅតាមនីតិវិធីដែលបានអនុវត្តកន្លងមកស្តីពីការស្នើសុំដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ។

**សំណើសុំលះបង់សិទ្ធមានវត្តមាននៅក្នុងអំឡុងពេលនៃការធ្វើបទបង្ហាញលើឯកសារ**

មេធាវីការពារក្តី ខៀវ សំផន បានជូនដំណឹងថា ជនជាប់ចោទ ខៀវ សំផន ស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៃការដេញដោលលើឯកសារ ដោយសារតែមូលហេតុសុខភាព។ អង្គជំនុំជម្រះបានបញ្ជាក់ថា អង្គជំនុំជម្រះនឹងជូនដំណឹងអំពីសេចក្តីសម្រេចរបស់ខ្លួននៅពេលរសៀល បន្ទាប់ពីទទួលបានរបាយការណ៍ពិនិត្យសុខភាពរបស់ជនជាប់ចោទ ខៀវ សំផន។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតិឱ្យ ជនជាប់ចោទ អៀង សារី ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍រៀបចំប្រព័ន្ធសោតទស្សន៍ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ បានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។
- អង្គជំនុំជម្រះសម្រេចបន្តកិច្ចដំណើរការនីតិវិធីដោយមិនមានវត្តមានជនជាប់ចោទ នួន ជា តាមការយល់ព្រមពីជនជាប់ចោទ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ បានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនសាក្សី AL ROCKOFF ត្រឡប់ទៅកាន់លំនៅដ្ឋានគាត់ វិញដោយសារតែសក្ខីកម្មរបស់គាត់បានបញ្ចប់។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំជនជាប់ចោទ អៀង សារី មកកាន់បន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និង ខៀវ សំផន មកកាន់បន្ទប់សវនាការនៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៣។

| **កាលបរិច្ឆេទបន្តសវនាការ៖** |
| --- |
| សវនាការនឹងបន្តនៅថ្ងៃ ពុធ ទី ៣០ ខែ មករា ឆ្នាំ ២០១៣ វេលាម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣
ក្រឡាបញ្ជី សវនាការ

សែ គុលទុឡ្លី Roger PHILLIPS